**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តឧត្តរមានជ័យ**
សំណុំរឿងរដ្ឋប្បវេណីលេខ ១១៣
ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២
សាលក្រមរដ្ឋប្បវេណី
លេខ ១០ "ខ"/ ៤៤
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តឧត្តរមានជ័យ

បានបើកនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ១០ និង ៣០ នាទី ព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រម**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

**-ដើមចោទឈ្មោះ** [redacted] ស៊ុលគីត្តី ភេទប្រុស អាយុ៣១ឆ្នាំ មុខរបរអាជីវករ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted]។

-លោកមេធាវី [redacted] ជាមេធាវី នៃក្រុមមេធាវី [redacted] មានការិយាល័យ[redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ។

**-ចុងចម្លើយឈ្មោះ** [redacted] ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅ [redacted]។

-លោកមេធាវី [redacted] និងលោកមេធាវី [redacted] មានការិយាល័យមេធាវី [redacted] មានទីតាំងស្ថិតនៅ [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ។

## អង្គហេតុ និង ចំណុចវិវាទ

### ១.ការទាមទាររបស់ដើមចោទ៖

១.១.ប្តឹងទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ សងប្រាក់ភាគហ៊ុន ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក។

១.២.សុំអនុវត្តជាបណ្តោះអាសន្នលើប្រាក់ភាគហ៊ុន ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក។

១.៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

### ២.ការពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទ និងចុងចម្លើយ បានចូលហ៊ុនគ្នា ដើម្បីបើកហាងសាច់អាំងប៊ីងស្ហោរទឹកកាពិ ដោយសារមានការទុកចិត្តគ្នា ទើបមិនបានធ្វើកិច្ចសន្យានោះទេ។ នៅពេលដែលចាប់ផ្តើមបើកហាង ដើមចោទបានទិញសម្ភារៈមួយចំនួនដែលដើមចោទបានបង់រំលោះ ដើម្បីយកមកតុបតែងក្នុងហាង ដោយចេញប្រាក់ផ្ទាល់ខ្លួន។ ក្រោយពីហាងបានបើកដំណើរការបានមួយរយៈ ក៏បានបញ្ហាប៉ះពាល់សម្ព័ន្ធគ្នាបន្តិចបន្តួច ពេលនោះដើមចោទបាននិយាយថា បើប្រគល់ប្រាក់ឱ្យចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក និងប្រគល់សម្ភារៈដែលដើមចោទបានបង់រំលោះមកឱ្យដើមចោទវិញ ដើមចោទនឹងព្រមប្រគល់ភាគហ៊ុនទាំងអស់ក្នុងហាងឱ្យទៅចុងចម្លើយ គ្រប់គ្រងម្នាក់ឯង ពេលនោះចុងចម្លើយសុំពេលរយៈ

Scanned with CamScanner

ពេល កន្លះខែ គ្រប់រយៈពេលដើមចោទឆាតសួរចុងចម្លើយពន្យាពីមួយខែទៅមួយខែ រហូតមកដល់ពេលនេះ ហើយចុងចម្លើយក៏មិនព្រមបែងចែកភាគហ៊ុនមកឱ្យដើមចោទ ផងដែរ។

## ៣.ចំណុចវិវាទ

**តើការទាមទាររបស់ដើមចោទមានមូលហេតុត្រឹមត្រូវដែរឬទេ?**

## ៤.ការអះអាងរបស់គាគី

**+ដើមចោទឈ្មោះ** [redacted] ភេទប្រុស អាយុ៣២ឆ្នាំ បានថ្លែងការណ៍ថា៖ ខ្លួនបានចរចារ ដោយទាមទារប្រាក់ ចំនួន២ម៉ឺនដុល្លាអាមេរិក គាត់សុំកន្លះខែ។ កន្លះខែក្រោយមកឆាតសួរគាត់គ្មានប្រាក់ឱ្យខ្លួនទេ។ ពេលនេះខ្លួនសុំទាមទារឱ្យចុងចម្លើយសងប្រាក់ ចំនួន ២ម៉ឺនដុល្លាអាមេរិក ពេលចូលហ៊ុនគ្នា មិនបានធ្វើកិច្ចសន្យានោះទេ តែមានសាក្សី។

**+លោក** [redacted] **ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ** បានថ្លែងការណ៍ថា៖ មូលហេតុដែលខ្លួនមិនបានដាក់ភស្តុតាងនោះ ព្រោះចុងចម្លើយបានទទួលស្គាល់រួចរាល់ហើយ ហើយការទទួលស្គាល់របស់គាត់បានក្តោបអត្ថន័យទាំងមូល។

**+លោក** [redacted] **ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ** បានថ្លែងការណ៍ថា៖ តាមការអះអាងរបស់ដើមចោទ មានភាពផ្ទុយគ្នាពីក្នុងពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ទោះជាយ៉ាងណាក៏ដោយ ការទាមទារឱ្យចុងចម្លើយសងប្រាក់ ចំនួន ២ម៉ឺនដុល្លាអាមេរិក ដោយផ្អែកលើអ្វី ដោយគ្មានកិច្ចសន្យា នោះទេ។ ហើយប្រាក់ចូលហ៊ុនគ្នាមិនបានកំណត់យ៉ាងពិតប្រាកដផងដែរ។ ការទាមទាររបស់ដើមចោទ ចុងចម្លើយពុំអាចកំណត់បានថា សងត្រឹមកម្រិតណានោះទេ ហើយអាជីវកម្មក៏មិនទាន់បានប្រាក់ចំណេញនោះទេ ដោយដើមចោទចាក់ចេញដោយពុំទទួលខុសត្រូវ។ ក្នុងនីតិវិធីត្រៀម គាត់ព្រមទទួលស្គាល់ថា សង ២ម៉ឺនដុល្លាអាមេរិក ដោយសារពេលនោះ គាត់ជឿជាក់ថា សងបាន តែផ្ទុយពីការគិតរបស់គាត់។ ចុងចម្លើយសុំច្រានចោលការទាមទារ។

**+លោក** [redacted] **ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ** បានថ្លែងការណ៍ថា៖ ចុងចម្លើយព្យាយាមគេចវេស ដោយគាត់ចង់កាន់កាប់ភាគហ៊ុន ម្នាក់ឯង ហើយមកដល់ពេលនេះ បើអាជីវកម្មមិនទទួលបានប្រាក់ចំណេញ ក៏គាត់មិនអាចបន្តបានដែរ។ ដោយការទាមទារ ប្រាក់ចំនួន ២ម៉ឺនដុល្លាអាមេរិក គឺមានភាពសមរម្យ។

**+លោក** [redacted] **ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ** បានថ្លែងការណ៍ថា៖ ប្រសិនបើអាចចាកចេញកូនក្តីខ្លួន ទាមទារ ២៥.០០០ ដុល្លាអាមេរិក ដោយគាត់ចំណាយលើហាងនោះច្រើន។

**+លោក** [redacted] **ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ** បានថ្លែងការណ៍ថា៖ ចុងចម្លើយនឹងដើមចោទបានដាក់ទុន រកស៊ីជាមួយគ្នា មែន តែមិនបានធ្វើលិខិតយថាភូតនោះទេ ដោយធ្វើកិច្ចសន្យាផ្ទាល់មាត់ ហើយដើមចោទមិនបានបង្ហាញថា ចូលហ៊ុនប៉ុន្មាននោះទេ។ ដូច្នេះសុំធ្វើការច្រានចោលការទាមទារ។

**+លោក** [redacted] **ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ** បានថ្លែងការណ៍ថា៖ ខ្លួនទាមទារប្រាក់ចំនួន ២ម៉ឺនដុល្លាអាមេរិក និងសុំអនុវត្តជាបណ្តោះអាសន្ន។ ចំណែកឯចំណុច ទី២ និងចំណុច ទី៣ នៃពាក្យបណ្តឹងចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ មិនធ្វើការទាមទារទៀតនោះទេ។

**+លោក** [redacted] **ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ** បានថ្លែងការណ៍ថា៖ សូមបដិសេធការទាមទារ ដោយហេតុថា ពុំមានមូលហេតុចាំបាច់ តាមមាត្រា ១៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះទេ។



Scanned with CamScanner

+លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍ថា៖ កូនក្តីរបស់ខ្លួន តែងតែមានចេតនាក្នុងការសម្របសម្រួលរកដំណោះស្រាយ តែចុងចម្លើយនៅតែមិនមានបំណុងចរចារនោះទេ។

+លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍ថា៖ ផ្អែកតាមអង្គហេតុ និងអង្គច្បាប់ ឃើញថា កូនក្តីរបស់ខ្លួន និងចុងចម្លើយ បានចូលហ៊ុនគ្នា មែន មូលហេតុដែលកូនក្តីរបស់ខ្លួន ចាកចេញដោយហេតុថា ចុងចម្លើយតែងតែឈ្លោះគ្នាជាមួយ បុគ្គលិករហូត ទើបកូនក្តីរបស់ខ្លួន សុំដកភាគហ៊ុន និងសុំទាមទារប្រាក់ ចំនួន ២ម៉ឺនដុល្លាអាមេរិក វិញ។ ហើយចុងចម្លើយក៏បានយល់ព្រម តែចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមការសន្យានោះទេ។ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ សុំទាមទារប្រាក់ចំនួន ២ម៉ឺនដុល្លាអាមេរិក និងសុំអនុវត្តជាបណ្តោះអាសន្ន។

+លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានថ្លែងការណ៍ថា៖ តាមការទាមទារប្រាក់ចំនួន ២ម៉ឺនដុល្លអាមេរិក ថ្លៃភាគហ៊ុន ការបើកហាងរកស៊ីជាមួយគ្នា បានដាក់ប្រាក់រួមគ្នា ដើម្បីឱ្យអាជីវកម្មដំណើរការ ភាគីទាំងពីរ បានដាក់ប្រាក់ដោយពុំបានកំណត់។ ការទាមទារ ២ម៉ឺនដុល្លាអាមេរិក ពីចុងចម្លើយ ឃើញថា អាជីវកម្មមិនទាន់ទទួលបានប្រាក់ចំណេញនោះទេ ចុងចម្លើយពុំមានលទ្ធភាពសងនូវដើមទុន ទៅដើមចោទនោះទេ ព្រោះប្រាក់បានចំណាយទៅលើការរកស៊ីអស់ហើយ។ វាជាភាពមិនច្បាស់លាស់ហើយដើមទុន និងការទាមទារពុំមានភស្តុតាង។ កូនក្តីរបស់ខ្លួន ក៏បានព្យាយាមរកដំណោះស្រាយផងដែរ។ ដូច្នេះសុំច្រានចោលការទាមទាររបស់ដើមចោទចោលទាំងស្រុង។

## សំអាងហេតុ

តាមលទ្ធផលនៃការការសាកសួរគូភាគី និងលទ្ធផលនៃការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

-ដើមចោទ ទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] ឡង់ឌី ភេទប្រុស អាយុ៣០ឆ្នាំ សងប្រាក់ភាគហ៊ុន ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក។ គប្បីតុលាការ ពិចារណា និងសម្រេចតាមការទាមទាររបស់ដើមចោទ ដោយហេតុថា ចុងចម្លើយក៏បានទទួលស្គាល់នូវភាគហ៊ុនរបស់ដើមចោទ មានចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក និងបានបង្ហាញនូវឆន្ទៈក្នុងការចេញសងភាគហ៊ុន មកឱ្យដើមចោទចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេតរិក ផងដែរ ដោយពេលនោះចុងចម្លើយសុំពេលក្នុងការសងភាគហ៊ុន ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក មកឱ្យដើមចោទ រយៈពេលកន្លះខែ។ ប៉ុន្តែពេលកាលបរិច្ឆេទដែលបានកំណត់មកដល់ ចុងចម្លើយមិនបានអនុវត្តតាមការសន្យានោះទេ រហូតមកដល់ពេលបច្ចុប្បន្ន។ ដូច្នេះ គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

-ដើមចោទ សុំអនុវត្តជាបណ្តោះអាសន្នលើប្រាក់ភាគហ៊ុន ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក។ គប្បីតុលាការពិចារណា និងសម្រេចតាមស្នើសុំរបស់ដើមចោទ ដោយផ្អែកតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-ចំពោះប្រាក់ប្រដាប់ក្តី យោងតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីសម្រេចឱ្យចុងចម្លើយជាអ្នកទទួលបន្ទុក។

## សេចក្តីសម្រេចបញ្ចប់

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ឡង់ឌី ភេទប្រុស អាយុ៣០ឆ្នាំ សងប្រាក់ ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លាអាមេរិក មកឱ្យដើមចោទឈ្មោះ [redacted] ស៊ុលគីត្តិ ភេទប្រុស អាយុ៣២ឆ្នាំ។

២.ប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ត្រង់ចំណុចទី១ នៃសេចក្តីសម្រេចនេះ។



Scanned with CamScanner

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ ចំពោះមុខដើមចោទ និងចុងចម្លើយ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ១៣ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជី** **ចៅក្រម**

---

**បានឃើញ**

ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

**ចៅក្រម**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១៣ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner